01375515

**Declassified to Public**
**28 November 2018**

លេខ: D226

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 10 / 01 / 2017
ម៉ោង (Time/Heure) : 15:25
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

**សំណុំរឿងលេខ៖ ០០៣/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស**

ចំពោះមុខ ៖ **សហចៅក្រមស៊ើបអង្កេត**

កាលបរិច្ឆេទ ៖ **ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៧**

ភាសា ៖ **ខ្មែរ & អង់គ្លេស [អង់គ្លេស ភាសាដើម]**

ចំណាត់ថ្នាក់ឯកសារ ៖ **សម្ងាត់**

# ដីកាសម្រេចកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរយោងតាមវិធានផ្ទៃក្នុង ៦៦ស្ទួន

**ផ្ញើជូន ៖**

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**មេធាវីការពារក្តី មាស មុត**
អាង ឧត្តម
Michael G. KARNAVAS

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
ជេត វណ្ណលី
ហុង គឹមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន ស៊ីវ៉ន
ទី ស្រីនណា
វ៉ែន ពៅ
Laure DESFORGES
Isabelle DURAND
Yiqiang LIU
Martine JACQUIN
Lyma NGUYEN
Nushin SARKARATI

## I. **ប្រវត្តិនីតិវិធី**

១. ករណីខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត (“ស.ច.ស”) នៅក្នុងសំណុំរឿងនេះ បានចុះបញ្ជីនៅថ្ងៃទី០៧ និង ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣ និង ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០១៤។

២. នៅថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៦ នៅក្នុង*សំណើសុំមតិយោបល់ទាក់ទងនឹងការចោទប្រកាន់អំពីអង្គហេតុដែលនឹងមិនស៊ើបអង្កេតថែមទៀតទេ* (“សំណើសុំមតិយោបល់”) ខ្ញុំបានជូនដំណឹងភាគីទាំងអស់ អំពីគោលបំណងរបស់ខ្ញុំដែលមិនចង់ស៊ើបអង្កេតថែមទៀតលើអង្គហេតុមួយចំនួន[1]។

៣. នៅថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៦ មាស មុត បានដាក់មតិយោបល់របស់គាត់[2] ហើយនៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៦ សហព្រះរាជអាជ្ញាអន្តរជាតិ (“ស.ព.អ”) បានដាក់មតិយោបល់របស់គាត់[3]។

៤. នៅថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១៦ នៅក្នុង*សេចក្តីជូនដំណឹងអំពីការផ្អាកកិច្ចស៊ើបសួរទាក់ទងនឹងការចោទប្រកាន់នីមួយៗ*(“សេចក្តីជូនដំណឹងអំពីការផ្អាកកិច្ចស៊ើបសួរ”)[4] ខ្ញុំបានជូនដំណឹងភាគីទាំងអស់ថា ខ្ញុំនឹងមិនស៊ើបអង្កេតថែមទៀតលើអង្គហេតុដូចខាងក្រោមដែលបានចោទនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ២[5] និងដីកាសន្និដ្ឋានបញ្ជូនរឿង

---

[1]សំណុំរឿង ០០៣ ឯកសារ D184 *សំណើសុំមតិយោបល់ទាក់ទងនឹងការចោទប្រកាន់អំពីអង្គហេតុដែលនឹងមិនស៊ើបអង្កេតថែមទៀតទេ* ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៦ (“សំណើសុំមតិយោបល់”)។

[2]សំណុំរឿង ០០៣ ឯកសារ D184/1 *លិខិតរបស់ មាស មុត ឆ្លើយតបទៅនឹងសំណើសុំមតិយោបល់ទាក់ទងនឹង អង្គហេតុដែលត្រូវបានចោទប្រកាន់ដែលនឹងមិនត្រូវបានស៊ើបអង្កេតបន្ថែមទៀត* ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៦ ទំព័រ ៥(“លិខិតរបស់មេធាវីការពារក្តី”)។

[3]សំណុំរឿង ០០៣ ឯកសារ D184/2 *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសំណើរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិសុំមតិយោបល់ទាក់ទងនឹងអង្គហេតុចោទប្រកាន់ដែលមិនត្រូវស៊ើបអង្កេតបន្ថែម* ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៦ (“ចម្លើយតប”) កថាខណ្ឌ ៣, ១៥-២១។

[4]សំណុំរឿង ០០៤ ឯកសារ D184/3 *សេចក្តីជូនដំណឹងអំពីការផ្អាកកិច្ចស៊ើបសួរទាក់ទងនឹងការចោទប្រកាន់នីមួយៗ* ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១៦។ គួរកត់សម្គាល់ថា ការចោទប្រកាន់នានាគឺសំដៅលើអង្គហេតុមួយ។

[5]សំណុំរឿង ០០៣ ឯកសារ D1 *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ២ របស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងនឹងកងទ័ពបដិវត្តកម្ពុជា* ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ (“ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ”)។

ឲ្យស៊ើបសួរបន្ថែមរបស់ ស.ព.អ[6] ដែលជាបឋមបង្ហាញឲ្យឃើញថាអាចអនុវត្តវិធានផ្ទៃក្នុង ៦៦ *ស្ទួន*៖

- **អង្គហេតុទី ១**- ការចោទប្រកាន់ទាំងអស់ទាក់ទងនឹងមន្ទីរសន្តិសុខ ស-២២[7]។
- **អង្គហេតុទី ២**- ការចោទប្រកាន់ទាំងអស់ទាក់ទងនឹងការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង[8]។
- **អង្គហេតុទី ៦**-ការចោទប្រកាន់ទាំងអស់ទាក់ទងនឹងទីតាំងសម្លាប់មនុស្ស ស្ទឹងតូច[9]។
- **អង្គហេតុទី ៧**-ការចោទប្រកាន់ទាំងអស់ទាក់ទងនឹងការចូលរួមរបស់ ក.ប.ក នៅក្នុង "ការបោសសម្អាត"ភូមិភាគកណ្តាល ភូមិភាគឧត្តរថ្មី និងភូមិភាគបូព៌ា ដោយមិនរាប់បញ្ចូលការចោទប្រកាន់អំពីការបោសសម្អាតសមាជិកនៅកង/អង្គភាព របស់ ក.ប.ក ដែលមានទីតាំងនៅតំបន់ទាំងនោះទេ[10]។

៥. នៅថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ខ្ញុំបានជូនដំណឹងភាគីទាំងអស់អំពីគោលបំណងរបស់ខ្ញុំដែលចង់ដកអង្គហេតុ ១, ២, ៦ និង ៧ ចេញពីកិច្ចស៊ើបសួរយោងតាមវិធានផ្ទៃក្នុង ៦៦*ស្ទួន* ("សេចក្តីជូនដំណឹងយោងតាមវិធាន ៦៦*ស្ទួន*")នៅពេលបិទកិច្ចស៊ើបសួរ[11]។

៦. នៅថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ស.ព.អ បានដាក់សេចក្តីសន្និដ្ឋានដែលបង្ហាញថា គាត់មិនជំទាស់ជាមួយនឹងការដកចេញនូវអង្គហេតុ ១, ២, ៦ និង ៧ ឡើយ ហើយបានឯកភាពថាអង្គហេតុដែលនៅសេសសល់គឺតំណាងឲ្យវិសាលភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម តាមភូមិសាស្ត្រ ពេលវេលា និងអង្គសេចក្តី[12]។ មេធាវីការពារក្តី មិនបានដាក់សារតបណាមួយឡើយ។

---

[6]សំណុំរឿង ០០៣ ឯកសារ D120 *ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់របស់សហព្រះរាជអាជ្ញាអន្តរជាតិ ស្តីពីទីតាំងឧក្រិដ្ឋកម្មនានាទាក់ទងនឹងសំណុំរឿង ០០៣* ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤។

[7]ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ កថាខណ្ឌ ៤៦។

[8]ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ កថាខណ្ឌ ៤៧។

[9]ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ កថាខណ្ឌ ៦៦។

[10]ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ កថាខណ្ឌ ៦៦។

[11]សំណុំរឿង០០៣ ឯកសារD184/4 *សេចក្តីជូនដំណឹងយោងតាមវិធានផ្ទៃក្នុង ៦៦ស្ទួន(២)* ថ្ងៃទី ២២ ខែវិច្ឆិកា ឆ្នាំ២០១៦។

[12]សំណុំរឿង ០០៤ ឯកសារ D184/4/1 *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសេចក្តីជូនដំណឹងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិអនុលោមតាមវិធាន ៦៦ ស្ទួន(២)* ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១៦។

II. **ពិភាក្សា**

៧. វិធាន ៦៦*ស្ទួន* (១) ចែងថា នៅពេលដែលជូនដំណឹងអំពីការបញ្ចប់កិច្ចស៊ើបសួរ ស.ច.ស អាចសម្រេចកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរ ដោយដកចេញនូវអង្គហេតុមួយចំនួន ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។

៨. នៅថ្ងៃនេះ យោងតាមវិធានផ្ទៃក្នុង ៦៦(១) ខ្ញុំជូនដំណឹងភាគីទាំងអស់ថា កិច្ចស៊ើបសួរប្រឆាំង មាស មុត បានបញ្ចប់។ ហេតុនេះ កិច្ចស៊ើបសួរនេះដល់ពេលដែលត្រូវចេញដីកាសម្រេច យោងតាមវិធានផ្ទៃក្នុង ៦៦*ស្ទួន*។

៩. ខ្ញុំបានសម្រេចដកអង្គហេតុ ១, ២, ៦ និង ៧ ចេញពីកិច្ចស៊ើបសួរ យោងតាមវិធានផ្ទៃក្នុង ៦៦ *ស្ទួន* តាមសំអាងហេតុដូចបានបញ្ជាក់នៅក្នុងសេចក្តីជូនដំណឹងអំពីការផ្អាកកិច្ចស៊ើបសួរ និង សេចក្តីជូនដំណឹងយោងតាមវិធាន ៦៦*ស្ទួន*។

១០. ខ្ញុំយល់ឃើញថា អង្គហេតុដែលនៅសេសសល់គឺតំណាងឱ្យវិសាលភាពនៃដីកាសន្និដ្ឋាន តាមភូមិសាស្ត្រ ពេលវេលា និងអង្គសេចក្តីទាក់ទងនឹងលក្ខណៈ និងទំហំនៃឧក្រិដ្ឋកម្ម និងប្រភេទជនរងគ្រោះ។

១១. ដូចខ្ញុំធ្លាប់បានបញ្ជាក់ពីមុនរួចហើយ វិធានផ្ទៃក្នុង ៦៦ *ស្ទួន* (៥) បញ្ជាក់ច្បាស់ថា នៅពេលដែលដកអង្គហេតុចេញ ភស្តុតាងពាក់ព័ន្ធនឹងអង្គហេតុដែលបានដកចេញទាំងនេះនៅតែអាចប្រើប្រាស់ជាមូលដ្ឋានបានឱ្យតែពាក់ព័ន្ធនឹងអង្គហេតុដែលនៅសេសសល់។

១២. ការដកចេញនូវអង្គហេតុ ១, ២, ៦ និង ៧ នឹងមិនប៉ះពាល់ដល់ឋានៈរបស់ដើមបណ្តឹងរដ្ឋប្បវេណី ឬសិទ្ធិរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងការចូលរួមកិច្ចស៊ើបសួរឡើយ។

**តាមសំអាងហេតុខាងលើ ខ្ញុំ៖**

១៣. **សម្រេច**ដកអង្គហេតុ ១, ២, ៦ និង ៧ ចេញពីកិច្ចស៊ើបសួរយោងតាមវិធានផ្ទៃក្នុង ៦៦*ស្ទួន*។

ភ្នំពេញ ថ្ងៃទី ៣០ មករា ឆ្នាំ ២០១៧

**ចៅក្រម Michael Bohlander**

**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**

**International Co- Investigating Judge**

**Co-juge d'instruction International**